# ពិធីចុះហត្ថលេខា
# លើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលស៊ុយអែត
# ស្តីពីការគាំទ្រកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃអង្គារ ទី១០ ខែឧសភា ឆ្នាំ២០១១

---

## មតិសំណេះសំណាលរបស់ឯកឧត្តម **ស ខេង**
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លោកជំទាវឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍
- ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយដ៏ក្រៃលែង ដែលបានអញ្ជើញឱ្យចូលរួមជាមួយនិងឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងរដ្ឋាភិបាលស៊ុយអែត តំណាងដោយលោកជំទាវ **អាន ហុកលុន** (**Anne Hoglund**) ឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

ស៊ុយអែត គឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយ ក្នុងចំណោមដៃគូអភិវឌ្ឍន៍នានា ដែលបានជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។ ស៊ុយអែត មិនត្រឹមតែជាដៃគូអភិវឌ្ឍន៍នាំមុខលើការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឈានទៅសម្រេចបាននូវកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែស៊ុយអែតបានជួយធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានាផ្សេងទៀតដើម្បីចូលរួមក្នុងការគាំទ្រនេះ។ យើងបានដើរលើផ្លូវដ៏វែងឆ្ងាយជាមួយគ្នា គឺចាប់តាំងពីពេលបង្កើតក្រុមប្រឹក្សាឃុំសង្កាត់តាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ហើយយើងក៏បានផ្តល់មូលនិធិរួមគ្នាដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់ទាំងនោះ រួមជាមួយនឹងជំនួយពីដៃគូអភិវឌ្ឍន៍នានាផ្សេងទៀតផងដែរ។ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងរួមគ្នានេះ។ បច្ចុប្បន្ន យើងមានក្រុមប្រឹក្សាឃុំសង្កាត់ ដែលមានកិច្ចដំណើរការពេញលេញ និងប្រកបដោយនិរន្តរភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងផ្តល់សេវាចាំបាច់នានាដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

នៅពេលយើងបង្កើតបានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមូលដ្ឋានស្នូលដ៏រឹងមាំមួយនៃអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បច្ចុប្បន្ននេះ យើងបានពង្រីកកំណែទម្រង់នេះនៅថ្នាក់ក្រុង ស្រុក និងខេត្ត រាជធានីបន្ថែម

ទៀត។ បន្ទាប់ពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា យើងបាននាំគ្នាប្រឹងប្រែងធ្វើការយ៉ាងខ្លាំងក្លា ក្នុងការរៀបចំផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិ ដែលយើងទាំងអស់គ្នាហៅថា "**ផអ៣**" ។ **ផអ៣**នេះ ត្រូវបានរៀបចំឡើងដោយមានការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ និងបានអនុម័តដោយ គ.ជ.អ.ប នៅខែវិច្ឆិកា ឆ្នាំ២០១០ ព្រមទាំងត្រូវបានដាក់ឱ្យធ្វើការវាយតម្លៃរួមគ្នាដោយដៃគូអភិវឌ្ឍន៍របស់យើងនៅដើមឆ្នាំ២០១១នេះ។ ទោះបីយ៉ាងនេះក្តី ខ្ញុំសូមគូសបញ្ជាក់ដោយស្មោះត្រង់ថា កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានតម្លៃខ្ពស់ណាស់ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្ត**ផអ៣**នេះ ដោយគ្មានការគាំទ្រយ៉ាងច្រើន និងជាបន្តបន្ទាប់ពីដៃគូអភិវឌ្ឍន៍ ដូចដែលយើងបាន និងកំពុងទទួលតាមរយៈកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានដែលបានចុះហត្ថលេខាក្នុងពេលនេះឡើយ។ ជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រនេះ។

ក្នុងខណៈដែលយើងមានសេចក្តីរីករាយក្នុងការទទួលបាននូវការគាំទ្រហិរញ្ញប្បទាន តាមរយៈកិច្ចព្រមព្រៀងនេះ យើងក៏សូមស្វាគមន៍ និងបើកចំហសម្រាប់ការគាំទ្រនានាក្រោមក្របខ័ណ្ឌនៃវិធីសាស្ត្រផ្អែកតាមកម្មវិធី ដែលបានឯកភាពគ្នារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលបាននាំមុខដោយស៊ុយអែត។

យើងយល់ដឹងយ៉ាងច្បាស់ថា រដ្ឋាភិបាលស៊ុយអែតត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនលើមូលនិធិដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងនេះ។ ក្នុងន័យនេះ ខ្ញុំសូមធានាអះអាងថា រាជរដ្ឋាភិបាលកម្ពុជានឹងប្រើប្រាស់មូលនិធិទាំងនេះសម្រាប់អនុវត្ត**ផអ៣** ដោយចាត់គ្រប់វិធានការចាំបាច់នានា ដើម្បីធានាថា មូលនិធិទាំងនេះនឹងត្រូវប្រើប្រាស់ដោយមានគណនេយ្យភាពយ៉ាងពេញលេញ ប្រើប្រាស់ឱ្យបានត្រឹមត្រូវ មានតម្លាភាព ប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិ ព្រមទាំងប្រកបដោយភាពសន្សំសំចៃខ្ពស់។ ជាងនេះទៅទៀត យើងនឹងផ្តល់រាល់របាយការណ៍ចាំបាច់នានា ដែលបង្ហាញអំពីលទ្ធផលនៃការវិនិយោគក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ប្រទេសកម្ពុជា។

ខ្ញុំសូមអនុញ្ញាតជម្រាបជូនថា ការគាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាមធ្យោបាយដ៏ស័ក្តិសិទ្ធមួយ ក្នុងដំណើរការឆ្ពោះទៅសម្រេចបានគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា។ ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅមូលដ្ឋាន នឹងចូលរួមយ៉ាងចំណែកយ៉ាងសំខាន់ក្នុងការលុបបំបាត់ភាពក្រីក្រ និងវិសមភាពសង្គម ដែលរួមបញ្ចូលទាំងវិសមភាពផ្នែកយេនឌ័រនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ការគាំទ្ររបស់រដ្ឋាភិបាលស៊ុយអែត និងសង្ឃឹមយ៉ាងមុតមាំថា នឹងបន្តទំនាក់ទំនងទ្វេភាគីយ៉ាងល្អប្រសើរបន្តទៀតរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលស៊ុយអែត។

---

សូមរដ្ឋាភិបាល និងប្រជាពលរដ្ឋស៊ុយអែតទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

សូមអរគុណ។